01039169

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 11 / 2014
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
**E1/242**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

ថ្ងៃ សុក្រ ទី ១៧ ខែ តុលា ឆ្នាំ ២០១៤

**សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២-ថ្ងៃទី ២២៥**

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, កញ្ញា ជា ស៊ីវហ៊ង |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជា លាង, លោក Nicholas KOUMJIAN, លោក William SMITH, លោក សេង ប៊ុនឃាង, លោក សេង លាង, កញ្ញា សុង ឆវ័ន្ត, លោក ស្រ៊ា រតនៈ, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK, លោក Salim NAKHJAVANI, លោក Joseph Andrew BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា, លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោកស្រី ម៉ុច សុវណ្ណារី, លោក ហុង គឹមសួន, លោក វ៉េន ពៅ, លោកស្រី ទី ស្រ៊ីនណា, លោកស្រី ស៊ីន សុវ៉ន, លោក Yiqiang LIU |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុធាវី |
| ផ្សេងៗ៖ លោក Russell HOPKINS, លោក Laurent SOULARD, លោកស្រី Kerri MILES, លោក Sheriffo JAMMEH, លោក Mario D'ALESSANDRO |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៤.៥៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៤៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៣ ម៉ោង ៤៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តី | អង្គជំនុំជម្រះ | ០៩.០៣ | ០៩.១៣ |
| ការអានបទចោទប្រកាន់ទៅលើជនជាប់ចោទ | ក្រឡាបញ្ជី | ០៩.១៣ | ០៩.២១ |
| ការសួរបញ្ជាក់អំពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប | អង្គជំនុំជម្រះ<br>ជនជាប់ចោទ នួន ជា<br>ជនជាប់ចោទ ខៀវ សំផន | ០៩.២១<br>០៩.២២<br>០៩.២៣ | ០៩.២១<br>០៩.២៣<br>០៩.២៥ |
| ការធ្វើសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់ | សហព្រះរាជអាជ្ញា | ០៩.២៦ | ១១.៤៥ |
| បញ្ហាទាក់ទងនឹងការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះ<br>មេធាវីនាំមុខ | ១០.២៧<br>១០.២៧ | ១០.២៧<br>១០.២៩ |
| ការឆ្លើយតបរបស់ជនជាប់ចោទ | ជនជាប់ចោទ នួន ជា<br>មេធាវីការពារក្តី នួន ជា | ១៣.៣១<br>១៤.០១ | ១៤.០០<br>១៤.០២ |

| | | | |
|---|---|---|---|
| | ជនជាប់ចោទ ខៀវ សំផន<br>មេធាវីការពារក្តី ខៀវ សំផន | ១៤.០៣<br>១៤.១៨ | ១៤.១៧<br>១៤.៣០ |
| ក្រុមមេធាវីការពារក្តីចាកចេញពីបន្ទប់សវនាការ | មេធាវីការពារក្តី នួនជា និង ខៀវ សំផន | ១៤.៣៨ | |
| ការកត់សម្គាល់ពាក់ព័ន្ធនឹងការធ្វើពហិការរបស់មេធាវីការពារក្តី | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខ | ១៤.៣៨<br>១៤.៤១ | ១៤.៤០<br>១៤.៤៤ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តី</u>**

ប្រធានអង្គជំនុំជម្រះ ប្រកាសបើកកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២។

**<u>ការអានបទចោទប្រកាន់ទៅលើ ជនជាប់ចោទ</u>**

ក្រឡាបញ្ជីសវនាការ បានអានបទចោទប្រកាន់ចំពោះជនជាប់ចោទ។

**<u>ការសួរបញ្ជាក់អំពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប</u>**

ប្រធានអង្គជំនុំជម្រះ សួរទៅកាន់ជនជាប់ចោទ អំពីបំណងរបស់ពួកគាត់ក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ជនជាប់ចោទ នួន ជា ប្រើប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់។ ជនជាប់ចោទ ខៀវ សំផន បង្ហាញថាគាត់នឹងឆ្លើយទៅនឹងសំនួររបស់ប្រធានអង្គជំនុំជម្រះ នៅពេលដែលគាត់ធ្វើសេចក្តីថ្លែងបើកគាត់រួចរាល់។

**<u>សេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញា</u>**

សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។

**<u>បញ្ហាទាក់ទងនឹងការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី</u>**

ប្រធានអង្គជំនុំជម្រះសួរទៅកាន់ មេធាវីនាំមុខ ឲ្យបញ្ជាក់ពីព័ត៌មានដែលទទួលបានដែលថា មានក្រុមដើមបណ្តឹងរដ្ឋប្បវេណីចង់ដាក់ញត្តិមកកាន់អង្គជំនុំជម្រះ។ មេធាវីនាំមុខ ថាគាត់នឹងទៅជួបជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសម្រាក។

**<u>ការឆ្លើយតបរបស់ជនជាប់ចោទ នួន ជា</u>**

ជនជាប់ចោទ នួន ជា បានធ្វើសេចក្តីថ្លែងបើកឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ គាត់ស្នើឲ្យ អង្គជំនុំជម្រះផ្អាកសវនាការរហូតដល់ មានសេចក្តីសម្រេចអំពីបណ្តឹងជំទាស់ ...

**<u>ការឆ្លើយតបរបស់ជនជាប់ចោទ ខៀវ សំផន និងមេធាវីការពារក្តី</u>**

ជនជាប់ចោទ ខៀវ សំផន បានធ្វើសេចក្តីថ្លែងបើកឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ ជនជាប់ចោទ ខៀវ សំផន ស្នើសុំមិនចូលរួមសវនាការក្នុងសំណុំរឿង ០០២/០២ រហូតដល់មេធាវីការពារក្តីគាត់បានដាក់សារណាបណ្តឹងសារទុក្ខទៅកាន់ អ.ជ.ត.ក ចប់សព្វគ្រប់។ បន្ទាប់មក មេធាវីការពារក្តី ខៀវ សំផន ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ហើយបានប្រកាសពីបំណងក្នុងការធ្វើពហិការមិនចូលរួមកិច្ចដំណើការនីតិវិធីដោយការបង្គាប់ពីកូនក្តីរបស់ខ្លួន។

**<u>ក្រុមមេធាវីការពារក្តីចាកចេញពីបន្ទប់សវនាការ</u>**

ក្រុមមេធាវីការពារក្តីទាំងពីរក្រុម ចាកចេញពីបន្ទប់សវនាការ។ ជនជាប់ចោទ បន្តនៅក្នុងសវនាការ។

**<u>ការកត់សម្គាល់ពាក់ព័ន្ធនឹង ការធ្វើពហិការរបស់មេធាវីការពារក្តី</u>**

សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យមេធាវីការពារក្តីមកកាន់សវនាការ។ បន្ទាប់មកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញថាវាជាប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ក្នុងការតម្រូវឱ្យក្រុមមេធាវីការពារក្តីមានវត្តមាន ហើយបង្ហាញថាសិទ្ធិក្នុងការការពារក្តីត្រូវថ្លឹងថ្លែងជាមួយនឹងសិទ្ធរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- បង្គាប់ឱ្យភាគីទាំងអស់ចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលរៀបចំធ្វើឡើងនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ នៅម៉ោង ៩ ព្រឹក។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ។

<u>កាលវេលាសវនាការបន្ត</u>

សវនាការត្រូវបានផ្អាក តុលាការនឹងជូនដំណឹងទៅភាគីនៅពេលក្រោយ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលវុឌ្ឍី** Roger PHILLIPS